**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង ព្រហ្មទណ្ឌ
លេខៈ១៥
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣
**<u>សាលដីកា</u>**
លេខៈ០៩
ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ............... ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក .................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ................

**<u>តំណាងមហាអយ្យការ</u>**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ របស់តុលាការកំពូល ។

**<u>ពីបទៈ</u>** អំពើអនាចារ និងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់លក់ដូរមនុស្សនិងធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

១-ជនជាប់ចោទឈ្មោះបាតជើរិត ក្លិនរិត (ហ)ក្លិហ្វ តុន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិអូស្ត្រាលី កើតនៅប្រទេសអូស្ត្រលី របរកស៊ីគ្រូបង្រៀន ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះBexeffon Better "រ" ហ្គយឈ្មោះLda grace Betterridge (រ)ក្រៅឃុំ

-មានមេធាវី លោក ...........

២-ជនជាប់ចោទឈ្មោះបាត ឡវ៉ើត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិបែលស្សិច សញ្ជាតិអូស្ត្រាលីកើតនៅប្រទេសអូស្ត្រាលី របររកស៊ីគ្រូបង្រៀន ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកក្នុងឃុំ ខេត្តសៀមរាប ឪពុកឈ្មោះEyrif Laywaert ម្តាយឈ្មោះLau Ralauwaert នៅលីវក្នុងឃុំ ។

-អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្តឹងសាទុក្ខ)

១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហាឡភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែទីលំនៅ សព្វថ្ងៃភូមិគោកដូង ក្រុម៦ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី អ្នកស្រី ............

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសឡ ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែទីលំនៅ សព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោក .............

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះនណគភេទស្រីអាយុ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើធ្មប ទីលំនៅសព្វថ្ងៃភូមិគោកដូង ក្រុម ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី អ្នកស្រី ............

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះបរភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មីលំនៅ សព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោក.............

៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឡជភេទប្រុសអាយុ២១ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មករ សំណង់ ទីលំនៅសព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោកលូង សុខា

៦-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឡជភេទស្រីអាយុ៧០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែទីលំនៅ សព្វថ្ងៃភូមិសង្កែមានជ័យ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប ។

-មានមេធាវី លោក..........

៧-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះតឡភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅ សព្វថ្ងៃភូមិគោកដូង ក្រុម៨ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-មានមេធាវី លោក.............

១-ជនរងគ្រោះឈ្មោះឡសមភេទស្រីអាយុ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

២-ជនរងគ្រោះឈ្មោះផសពហៅនាងកុមារី អាយុ១១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៣-ជនរងគ្រោះឈ្មោះតវភេទស្រីអាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៤-ជនរងគ្រោះឈ្មោះពលកុមារី អាយុ១១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៥-ជនរងគ្រោះឈ្មោះតលកកុមារី អាយុ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិសង្កែមានជ័យ ឃុំជីក្រែង ស្រុក-ខេត្តសៀមរាប ។

៦-ជនរងគ្រោះឈ្មោះនសខភេទស្រី អាយុ១៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៧-ជនរងគ្រោះឈ្មោះគសវកុមារី អាយុ១៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៨-ជនរងគ្រោះឈ្មោះកសវកុមារី អាយុ១២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

៩-ជនរងគ្រោះឈ្មោះពឡុភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

១០-ជនរងគ្រោះឈ្មោះវហៅស្រីពៅ ភេទស្រី អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោកដូង ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-តាមកំណត់ហេតុបណ្ដឹងចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះឡដថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះសឡ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះនសខៈឈ្មោះពឡថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះនរបរឿនហឡនិងកំណត់ហេតុបណ្ដឹង ចុះថ្ងៃឡើ០៩ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះតនប្រធានអង្គការewec ថាៈ ខ្លួនបានទទួលដំណឹងពីក្មេងស្រីឈ្មោះដលកជាអ្នកបោសសំអាតបន្ទប់ឱ្យជនបរទេសឈ្មោះមិកិ ហើយត្រូវបានជនបរទេសរូបនោះប្រព្រឹត្តិអំពើអនាចារមកលើខ្លួន ។ ដូច្នេះសូមឱ្យផ្ដន្ទាទោសជនល្មើសតាមច្បាប់ និងបង់ជំងឺចិត្តចំនួន ៥០០០ដុល្លារ(ប្រាំពាន់ដុល្លារ) ។

-បានឃើញដីកាសម្រេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ១១៧៣-០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ដែលបានសម្រេច :

-មិនអនុញ្ញាតិឱ្យឈ្មោះបាត់ឡរ៉ើត ដែលត្រូវចោទពីបទៈ

១-អំពើអនាចារ និងរំលោភសេពសន្ថវៈប្រព្រឹត្តនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ រហូតដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០២ ។

២-ប៉ុនប៉ងរំលោភសេពសន្ថវៈកាលពីខែកុម្ភៈ ឆ្នាំ២០០២ ប្រព្រឹត្តនៅភូមិថ្មី ឃុំស្វាយដង្គំស្រុកសៀមរាប ខេត្តសៀមរាប ។

៣-សញ្ចារិត ប្រព្រឹត្តនៅភូមិស្ទឹងថ្មី ភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងខែមេសា ឆ្នាំ ២០០២ ហើយជនជាប់ចោទនេះមិនអនុញ្ញាតិឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នឡើយ ។

-មិនអនុញ្ញាតិឱ្យឈ្មោះបាត់ជើរិត ក្លិនរិត ដែលត្រូវចោទពីបទៈ

១-អំពើអនាចារ និងរំលោភសេពសន្ថវៈប្រព្រឹត្តនៅ ភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ។

២-បើកកន្លែងប្រព្រឹត្តអំពើអនាចារ ឬអាសអាភាស និងសញ្ចារិត ប្រព្រឹត្តនៅ ភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ។

៣-បៀតបៀនកេរ្តិ៍ខ្មាស់ប្រព្រឹត្តនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងខែមេសា ឆ្នាំ ២០០២ និងថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ។

៤-ប្រើប្រាស់ដោយខុសច្បាប់រុក្ខជាតិដែលចាត់ទុកជាថ្នាំញៀន ប្រព្រឹត្តជាអចិន្ត្រៃយ៍នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ហើយជនជាប់ចោទនេះមិនអនុញ្ញាតិឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នឡើយ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០២របស់ឈ្មោះ........... មេធាវីការពារឱ្យជនជាប់ចោទប្ដឹងមិនសុខចិត្តពីដីកាសម្រេចលេខ១១៧៣-០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប លើដីកាសម្រេចទាំងមូល ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ បដិសេធមិនអនុញ្ញាតិលើពាក្យបណ្ដឹងសុំនៅក្រៅឃុំរបស់មេធាវីបានឡើយ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០២ របស់លោកមេធាវី........... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់ដីកាសម្រេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ១១៧៤/២០០២ ចុះថ្ងៃ ទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ឧត្តមានជ័យទុកជាបានការដដែល។

៣-បដិសេធដីកាសម្រេចមិនអនុញ្ញាតិឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ១១៧/២០០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ឧត្តមានជ័យ ចោលជាអសារបង់ ។

៤-អនុញ្ញាតិឱ្យឈ្មោះបាត់ធើរិត ក្លិនរិត (Beterridge elion Rix) ហៅក្លិហ្វតុន ភេទប្រុសអាយុ៣៥ឆ្នាំ សញ្ជាតិអូស្ត្រាលី របររកស៊ីគ្រូបង្រៀន ទីលំនៅមុនពេលចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលត្រូវចោទពីបទៈ

ក-អំពើអនាចារ និងរំលោភសេពសន្ថវៈ កាលពីថ្ងៃទី ខែមេសា ឆ្នាំ២០០២ នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ។

ខ-បើកកន្លែងប្រព្រឹត្តអំពើអនាចារអាសអាភាស និងជាសញ្ចារិត កាលពីដើមខែមេសា ឆ្នាំ២០០២ នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ។

គ-បៀតបៀនកេរ្តិ៍ខ្មាសនៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប គិតពីអំឡុងខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ ។

ឃ-ប្រើប្រាស់ដោយខុសច្បាប់នូវរុក្ខជាតិដែលចាត់ទុកជាថ្នាំញៀនប្រព្រឹត្តជាអចិន្ត្រៃយ៍នៅភូមិគ្រួស ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប គិតពីក្នុងអំឡុងខែមេសា ឆ្នាំ២០០២ រហូតដល់ថ្ងៃ០៣ ខែសីហា ឆ្នាំ២០០២ ហើយជននេះត្រូវឃុំឃាំងខេត្តសៀមរាប តាមដីកាឃុំខ្លួនលេខ១៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ និងដីកាលេខ៣៤៦ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ឱ្យឈ្មោះនៅក្រៅឃុំជាបណ្ដោះ អាសន្នសិន ។

៥-បង្គាប់ឱ្យសមត្ថកិច្ចដោះលែងឈ្មោះបាត់ធើរិត ក្លិនរិត (Beterridge eliont Rix) ហៅក្លិហ្វតុន ចេញពីមន្ទីឃុំឃាំងជាបន្ទាន់ប្រសិនបើឈ្មោះនេះពុំត្រូវឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

៦-សាលដីកានេះមានអនុភាពអនុវត្តភ្លាមៗទោះជាមានបណ្ដឹងសាទុក្ខក៏ដោយ ។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តសាលដីកព្រហ្មទលេខ០១"ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើចំណុចទី៣និងទី៥ នៃសេចក្តីសម្រេច ។

-បានឃើញសារណា ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍(ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញលិខិតបង្គាប់ឲ្យធ្វើសារណា ឆ្លើយតបចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូលបង្គាប់ឲ្យឈ្មោះបាត់ជើរិត ក្លីនរិត (ជាចុងបណ្តឹងសាទុក្ខ) ធ្វើសារណាឆ្លើយតបពីសារណារបស់ឯកឧត្តមអគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍ ។ ហើយលោក............. មេធាវីរបស់ខ្លួនបានទទួលនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៣ រួចហើយ ប៉ុន្តែពុំបានធ្វើសារណាតាមកំណត់ច្បាប់ទេ ដែលជាហេតុធ្វើឲ្យគ្មានសារណា ឆ្លើយតបរបស់ចុងបណ្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា៖ សាលាឧទ្ធរណ៍ សម្រេចឱ្យជនជាប់ចោទឈ្មោះបាត់ជើរិត ក្លិនរិត នៅក្រៅឃុំ ឃើញថាមិនត្រឹមត្រូវឡើយ ។

-ក្រឡាបញ្ជីអានសារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ នៅពេលជំនុំជំរះ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះហឡនៅពេលជំនុំជំរះថា៖ សុំឱ្យតុលាការដាក់ទោសលើជនជាប់ចោទមកដាក់គុកវិញ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសឡ នៅពេលជំនុំជំរះថា៖ បញ្ជូន ជនជាប់ចោទមកដាក់គុកនៅស្រុកខ្មែរវិញ សម្រេចតាមច្បាប់យល់ឃើញ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះនណគនៅពេលជំនុំជំរះថា នាងខ្ញុំមិនសុខចិត្តទេ សុខភាពកាន់តែទ្រុឌទ្រោមទៅៗដោយសារត្រូវថ្នាំញៀន ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះរវនៅពេលជំនុំជំរះ ថា៖ សុំឱ្យតុលាការសម្រេចទៅតាមច្បាប់ចុះ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឡជនៅពេលជំនុំជំរះថា៖ ខ្ញុំបាទមិនព្រម ប្អូនរបស់ខ្ញុំបាទធ្លាក់ខ្លួនឈឺ ខ្ញុំបាទគ្មានលុយមើលជំងឺទេ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះតឡនៅពេលជំនុំជំរះ ថា៖ សុំឱ្យតុលាការចាប់ជនជាប់ចោទមឃុំវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក........... មេធាវីការពារជនជាប់ចោទឈ្មោះបាតជើរិត ក្លីនរីត (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា៖ កូនក្តីខ្ញុំមិនប្រើប្រាស់គ្រឿងញៀន ព្រោះនៅផ្ទះកើតហេតុគ្មានភស្តុតាងទេណាមួយការជួលផ្ទះនេះពុំមែនកូនក្តីខ្លួនបាទទេ។ ម្យ៉ាងទៀតជនរងគ្រោះទាំងអស់មកចូលធ្វើការក្នុងផ្ទះនេះមានការយល់ព្រមដែរ ដោយបានជួរការងារជាមួយប្រាក់ខែ ពុំមានការគាបសង្កត់ពីកូនក្តីខ្ញុំបាទឡើយ ។ ខ្ញុំមានភស្តុតាងដូចជាសំបុត្រពេទ្យបានបញ្ជាក់ថា ជនរងគ្រោះឈ្មោះតលកពុំបានបាត់បង់ភាពបរិសុទ្ធ និងឈ្មោះឡសមជឿន សារ៉យ និងគឿន សារី ភាពបរិសុទ្ធបានបាត់បង់ទៅហើយ ។ ដូច្នោះកូនក្តីខ្ញុំគ្មានភស្តុតាងសំរាប់ដាក់បន្ទុកទេ សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះឃើញថាត្រឹមត្រូវសូមតម្កល់ សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក............ មេធាវីការពារជនរងគ្រោះឈ្មោះរវនៅពេលជំនុំជំរះថា ៖ តុលាការខេត្តសៀមរាបបានសម្រេចដល់អង្គសេចក្តីដាក់ទោសជនជាប់ចោទ១០ឆ្នាំហើយ ដូច្នេះតុលាការកំពូលមិនអាចសម្រេចផ្ទុយពីនេះបានទេសូមតុលាការ បដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់អ្នកស្រី........... ជាមេធាវីការពារជនរងគ្រោះឈ្មោះព្រេម ឡេម ពល និងនសខនៅពេលជំនុំជំរះថា : ការឱ្យជនជាប់ចោទនៅក្រៅឃុំនាំប៉ះពាល់ដល់នីតិវិធី អគ្គព្រះរាជអាជ្ញាប្តឹងសាទុក្ខហើយ សាលាឧទ្ធរណ៍នៅតែដោះលែងជនជាប់ចោទទៀត សូមតុលាការកំពូលសម្រេចចាប់ខ្លួនជនជាប់ចោទមកដាក់គុកវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក............ជាមេធាវីការពារជនរងគ្រោះឈ្មោះឡសមផសពតុន ប៉ាន់ តឿង លីកា,គឿន សារី និងឈ្មោះគឿន សារ៉យ នៅពេលជំនុំជំរះ ការឱ្យជនជាប់ចោទនៅក្រៅឃុំ មិនត្រឹមត្រូវវាខុសនឹងច្បាប់ បាត់បង់ពីសំណាងរដ្ឋប្បវេណីដែលត្រូវសង មកកូនក្តីខ្ញុំបាទ ។ ម្យ៉ាងតាមនីតិវិធី ការឱ្យជនជាប់ចោទនៅក្រៅឃុំត្រូវដាក់ប្រាក់ធានា ប៉ុន្តែក្នុងរឿងនេះពុំបានដាក់ប្រាក់ធានាទេ សូមតុលាការកំពូលសម្រេចឃុំខ្លួនលើជនជាប់ចោទវិញ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យករ អមតុលាការកំពូលថាៈ ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋច្រើន លើកច្រើនសារដែលច្បាប់ប្រទេសកម្ពុជាត្រូវហាមឃាត់ ។ ដូចច្នេះសូមក្រុមប្រឹក្សាជំនុំជំរះសម្រេចឃុំខ្លួនជនជាប់ចោទវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ចម្លើយរបស់ដើម បណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ មេធាវីជនរងគ្រោះ និងដើមបណ្តឹង រដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍បានប្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌ លេខ០១ "ច" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣និងទី៥ទេ ។ ដូច្នេះចំណុចក្រៅពីនេះបានចូលជាស្ថាពររួចហើយ តុលាការកំពូលមានសមត្ថកិច្ចនៅពេលនេះជំនុំជំរះតែចំណុចទី៣ និងទី៥ នៃសាលដីកាខាងលើប៉ុណ្ណោះ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធដីកាលេខ១១៧៤/២០០២ ចុះថ្ងៃទី០៤ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ហើយសម្រេចឱ្យជនជាប់ចោទឈ្មោះបាត់ធើរិត ក្លិនរិត (BATTERDGE CLINT REX) ហៅក្លកហ្វតុន នៅក្រៅឃុំបណ្តោះអាសន្នដោយអាងហេតុថា ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ក្នុងបទឧក្រិដ្ឋ ដូចការចោទប្រកាន់ហើយអាចមានអំពើបៀតបៀនកេរ្តិ៍ខ្មាស ដែលជាបទមជ្ឈិមប៉ុណ្ណោះនោះគឺជាការខុសឆ្គងមួយដ៏ធ្ងន់ធ្ងរ ពីព្រោះសាលាឧទ្ធរណ៍បានរំលោភអំណាចនៅលើរឿងអង្គសេចក្តីដែលស្ថិត

នៅក្នុងសមត្ថកិច្ចតុលាការខេត្តសៀមរាបនៅឡើយរួមមានទាំងបទមជ្ឈិមទាំងបទឧក្រិដ្ឋ គឺបទល្មើសដែលមានចែងនៅក្នុងមាត្រា៧ និង៨ នៃច្បាប់ស្តីពីការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៣៣ និង៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ព្រមទាំងមាត្រា៩៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប មិនទាន់បញ្ចប់ការស៊ើបអង្កេតផង បែរជាសាលាឧទ្ធរណ៍យល់ថា ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ ចោទទៅវិញ ។

-យល់ឃើញថា ជនជាប់ចោទពុំមានទីលំនៅអចិន្ត្រៃយ៍ និងពិតប្រាកដលើទឹកដីនៃព្រះរាជាណាចក្រ កម្ពុជាទេ ហើយក៏ពុំមានទ្រព្យសម្បត្តិ ឬ ប្រាក់កាសសំរាប់ធានាសំណងដល់ជនរងគ្រោះដើម្បីសុំនៅក្រៅឃុំដែរ ជាក់ស្តែងនៅពេលដែលសាលាឧទ្ធរណ៍សម្រេចឱ្យជននេះនៅក្រៅឃុំ ជននេះបានគេចខ្លួននិងពុំបានមក ចូលរួមនាសវនាការនេះទេ។ ដូច្នេះការ ដែលសាលាឧទ្ធរណ៍សម្រេចឱ្យជនជាប់ចោទឈ្មោះ( BATTERDGE LHNTT REX ) នៅក្រៅឃុំបណ្តោះអាសន្ន គឺជាការរំលោភលើលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ព្រមទាំងពុំបានសម្រេចឱ្យជនជាប់ចោទដាក់ប្រាក់ធានាដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានការទុកចិត្តនៅពេលដែលតុលាការសម្រេចសេចក្តីជាស្ថាពរដែរ ។

-យល់ឃើញថា មេធាវីជនជាប់ចោទឈ្មោះបាត់ជើរិត ក្លីនរិត បានទទួលលិខិតបង្គាប់ឱ្យធ្វើសារណា និងដីកាកោះឱ្យមកចូលរួមសវនាការនេះ តាមរយៈស្ថានទូតអូស្រ្តាលីប្រចាំកម្ពុជាហើយ ប៉ុន្តែសាមីខ្លួនពុំបានធ្វើសារណា និងពុំបានមកចូលរួមនាសវនាការនេះទេ ហើយតុលាការកំពូលក៏បានចាត់តាំងមេធាវីម្នាក់ឱ្យការពារ ឱ្យជនជាប់ចោទនៅពេលសវនាការនេះដែរ ។ ដូច្នេះតុលាការកំពូលជំនុំជំរះក៏បាំងមុខ ចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រីឡដជាម្តាយជនរងគ្រោះឈ្មោះតលកពុំបាន មកចូលរួមនាសវនាការនេះទេ ដោយមូលហេតុមានជំងឺ ប៉ុន្តែមេធាវីរបស់អ្នកស្រីបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះក៏បាំងមុខចាត់ទុកជាចំពោះមុខដែរ ។

-យល់ឃើញថា តុលាការកំពូលជំនុំជំរះនៅពេលនេះ តែលើបណ្តឹងសាទុក្ខរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ដែលមិនសុខចិត្តអំពីការសម្រេចឱ្យជនជាប់ចោទឈ្មោះបាត់ជើរិត ក្លិនរិត នៅក្រៅឃុំ។ ដូច្នេះតុលាការកំពូលក៏ពុំមានសមត្ថកិច្ចពិចារណាដល់អង្គសេចក្តីថា ជនជាប់ចោទមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន ឬពុំមានបានឡើយ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០១″ច″ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីត្រង់ចំណុចទី៣ និងទី៥ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេមក្តីចំពោះមុខទើបណ្តឹងរដ្ឋប្បវេណីឈ្មោះហាម ឡាក់, សឡ នួន ណាត្រី,រុន ឡាញ់(កូនប៉ិត រឿន) ឡដនិងតឿង ឡុំ កំបាំងមុខជនជាប់ចោទ ឈ្មោះបាត់ជើរិត ក្លិនរិត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះង៉ែត ជា ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០៣ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈចំណុចទី៣ និងទី៥ នៃសាលដីកព្រហ្មទណ្ឌលេខ០១″ច″ ចុះថ្ងៃទី០៨ ខែមករាឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដោយឥតបង្វិល ។

៣-បង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទធឈ្មោះបាត់ធើរិត ក្លិនរិត ហៅក្លីហ្វតុន (BATTERIDGE CLINT REXCLIFTON) ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិអូស្ត្រាលី ទីលំនៅមុនថ្ងៃចាប់ខ្លួននៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាន់លិខិតឆ្លងដែនលេខL8770706 យកទៅឃុំខ្លួននៅមន្ទីរឃុំឃាំងព្រៃសរ ជាបណ្តោះអាសន្ន រងចាំតុលាការសម្រេចដល់អង្គសេចក្តីជាស្ថាពរ ។

**<u>ពីបទៈ</u>**

ក/ ប្រព្រឹត្តិអំពើអនាចារ និងរំលោភសេពសន្ថវៈ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០២ ប្រព្រឹត្តិនៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

ខ/បើកកន្លែងប្រព្រឹត្តិអនាចារ និងជាសញ្ចារិត កាលពីដើមខែមេសា ឆ្នាំ២០០២នៅភូមិគ្រួសឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

គ/ បៀតបៀនកេរ្តិ៍ខ្មាស នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០២ ។

ឃ/ ប្រើប្រាស់រុក្ខជាតិដែលចាត់ទុកជាថ្នាំញៀនខុសច្បាប់ជាអចិន្ត្រៃយ៍ នៅភូមិគ្រួស ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ២០០២ ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០២ ។ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៧និង៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ពង្រាត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស មាត្រា៣៣ និង៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ព្រមទាំងមាត្រា៩៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការខេត្តសៀមរាប ដើម្បីបញ្ចូលក្នុងអង្គសេចក្តី ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ ។